ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៧០៧/អយក.ជាក

ថ្ងៃ សុក្រ ១៤កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤


**សូមគោរពជូន**

**ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំអនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានពន្យារពេលនៃកិច្ចដំណើរការរៀននិងបង្រៀនបន្ថែមមួយខែសម្រាប់អនុវត្តចាប់ពីឆ្នាំសិក្សា២០២៤-២០២៥ តទៅ។

**យោង ៖** -សេចក្តីណែនាំលេខ៥៩ អយក.សណន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា

-សេចក្តីណែនាំលេខ៦០ អយក.សណន ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជូន ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំ ស្តីពីដំណើរការគ្រឹះស្ថានបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅសាធារណៈក្នុងឆ្នាំសិក្សា២០២៣-២០២៤ ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣ និងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ ដែលមានរយៈពេល១០(ដប់)ខែ។ ដោយឡែក ចាប់ពីឆ្នាំសិក្សា២០២៤-២០២៥ តទៅ ក្រសួងនឹងរៀបចំចាប់ផ្តើមបើកបវេសនកាលនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៤ នឹងត្រូវបញ្ចប់ទៅវិញថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ ដែលមានរយៈពេល១១(ដប់មួយ)ខែ ក្នុងគោលបំណងធានាការអប់រំប្រកបដោយគុណភាព ព្រមទាំងឆ្លើយតបទៅនឹងបរិបទនៃការសិក្សារបស់ប្រទេសក្នុងតំបន់។ ដូចនេះ ជាហេតុធ្វើឱ្យជះឥទ្ធិពលយ៉ាងខ្លាំងដល់ការចំណាយដែលពាក់ព័ន្ធនឹងកិច្ចដំណើរការរៀននិងបង្រៀន មានជាអាទិ៍៖

- ប្រាក់ឧបត្ថម្ភគ្រូជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងការបង្រៀនថ្ងៃព្រហស្បតិ៍នៅបឋមសិក្សា
- ប្រាក់ម៉ោងបន្ថែមនៅមធ្យមសិក្សាចំណេះទូទៅ
- ការផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍
- ការផ្តល់ប្រាក់អាហារូបករណ៍របស់សិស្សអប់រំបច្ចេកទេស
- ប្រាក់ឧបត្ថម្ភប្រចាំខែរបស់សិស្សជនជាតិភាគតិចនិងសិស្សមានជីវភាពក្រីក្រ ដែលមកសិក្សានៅក្នុងអន្តេវាសិកដ្ឋាននៃអនុវិទ្យាល័យឬទីប្រជុំជនស្រុក ឃុំដែលមានអន្តេវាសិកដ្ឋាន



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- ប្រាក់ឧបត្ថម្ភលើការចំណាយសម្ភារៀននិងបង្រៀន ការហូបចុក ការស្នាក់នៅ សោហ៊ុយធ្វើដំណើរនិងថវិកាដំណើរការសាលារៀនសម្រាប់សិស្សនៅវិទ្យាល័យអប់រំពិសេស។ ដោយឡែករាល់មុខសញ្ញាចំណាយទាំងនេះ ជាគោលការណ៍សម្រាប់ការអនុវត្តបច្ចុប្បន្ន បានផ្តល់ជូនមានរយៈពេលត្រឹមចំនួន១០(ដប់)ខែនៃឆ្នាំសិក្សានីមួយៗ ប៉ុណ្ណោះ។

ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំអនុញ្ញាតជាគោលការណ៍ពី ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាផ្តល់ការពន្យារពេលនៃកិច្ចដំណើរការរៀននិងបង្រៀនបន្ថែមមួយខែសម្រាប់អនុវត្តចាប់ពីឆ្នាំសិក្សា២០២៤-២០២៥ តទៅ ដើម្បីបន្តនិរន្តរភាពការរៀននិងបង្រៀនឱ្យមានសង្គតិភាពទៅនឹងម៉ោងសិក្សារបស់ប្រទេសក្នុងតំបន់និងបំពេញនូវគម្លាតសមត្ថភាពរបស់សិស្សានុសិស្ស ជាពិសេសគឺលទ្ធផលនៃការសិក្សាត្រូវបានកែលម្អជាប្រចាំ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យលទ្ធភាពនិងអនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានពន្យារពេលនៃកិច្ចដំណើរការរៀននិងបង្រៀនបន្ថែមមួយខែសម្រាប់អនុវត្តចាប់ពីឆ្នាំសិក្សា២០២៤-២០២៥ តទៅ ដោយសេចក្តីអនុគ្រោះ។

សូម ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- -អគ្គលេខាធិការដ្ឋាន
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- -កាលប្បវត្តិ
- -ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ